# ការស្រាយបំភ្លឺនូវការយល់ច្រឡំនានា

*ប្រសិនបើទីតាំងអាជីវកម្មរបស់អ្នកបើកចំហជាសាធារណៈ នោះវាត្រូវតែមានលក្ខណៈងាយស្រួលសម្រាប់បុគ្គលដែលមានពិការភាពអាចចេញចូលបាន។ ការយល់ច្រឡំអំពីស្តង់ដារទាំងនេះ អាចធ្វើឱ្យអ្នកមានភាពមិនច្បាស់លាស់អំពីការអនុលោមតាមច្បាប់នៃទីតាំងរបស់អ្នក។ ដូច្នេះ ចូរយើងមកស្វែងយល់ពីការពិតទាំងអស់គ្នា៖*

## ច្បាប់ស្តីពីជនពិការរបស់សហរដ្ឋអាមេរិកឆ្នាំ 1990 (ADA)

*គឺជច្បាប់សិទ្ធិស៊ីវិលរបស់សហព័ន្ធ ដែលហាមឃាត់ការរើសអើងចំពោះបុគ្គលដែលមានពិការភាព និងតម្រូវឱ្យរាល់ទីកន្លែងស្នាក់នៅសាធារណៈ និងទីតាំងពាណិជ្ជកម្មទាំងអស់ ត្រូវតែមានលក្ខណៈងាយស្រួលសម្រាប់បុគ្គលដែលមានពិការភាពអាចចេញចូលបាន។*

## ច្បាប់សាងសង់រដ្ឋកាលីហ្វ័រញ៉ា (CALIFORNIA BUILDING CODE)

*រួមមាននូវបទប្បញ្ញត្តិស្តីពីលទ្ធភាពអាចចេញចូលបានពាក់ព័ន្ធនឹងការសាងសង់ ដែលជាស្តង់ដារសម្រាប់សំណង់ដែលអនុលោមតាមច្បាប់។ ការអនុលោមតាមច្បាប់នៃទីតាំងមួយ គឺផ្អែកទៅលើកំណែនៃច្បាប់សាងសង់រដ្ឋកាលីហ្វ័រញ៉ា ដែលបានចូលជាធរមាននៅពេលសាងសង់ ឬនៅពេលមានការកែប្រែសំណង់នោះ។*

| ការយល់ច្រឡំ | ការពិត |
| --- | --- |
| **អាជីវកម្មរបស់ខ្ញុំមិនចាំបាច់អនុលោមតាមច្បាប់នោះទេ ពីព្រោះសំណង់អគារនេះចាស់ហើយ។** | **មិនមានបទប្បញ្ញត្តិ "លើកលែង" (Safe Harbor) នោះឡើយ។**<br>"Safe harbor" គឺជាការយល់ឃើញថា លក្ខខណ្ឌតម្រូវនៃច្បាប់ ADA មិនត្រូវបានអនុវត្តចំពោះសំណង់អគារដែលបានសាងសង់មុនពេលច្បាប់ ADA ត្រូវបានបង្កើតឡើងនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការយល់ឃើញនេះគឺមិនត្រឹមត្រូវឡើយ។ ទោះបីជាសំណង់អគារនោះមានអាយុកាលចាស់ប៉ុនណា ឬមានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រយ៉ាងណាក៏ដោយ ប្រសិនបើវាបើកចំហជាសាធារណៈ អ្នកត្រូវតែផ្តល់លទ្ធភាពឱ្យជនពិការអាចចេញចូលទៅប្រើប្រាស់ទំនិញ និងសេវាកម្មដែលអ្នកផ្តល់ជូន។ អ្នកឯកទេសបញ្ជាក់ពីលទ្ធភាពអាចចេញចូលប្រើប្រាស់បាន (Certified Access Specialist, CASp) អាចប្រាប់អ្នកអំពីការផ្លាស់ប្តូរអ្វីខ្លះ ប្រសិនបើមាន ដែលចាំបាច់ត្រូវធ្វើ ដើម្បីឱ្យទីតាំងរបស់អ្នកអនុលោមតាមច្បាប់។ |
| ***អគារនេះជាកម្មសិទ្ធិរបស់អ្នកផ្សេង ដូច្នេះខ្ញុំមិនមានទំនួលខុសត្រូវចំពោះការរំលោភច្បាប់នោះទេ។*** | **ការអនុលោមតាមច្បាប់ មិនមែនជាទំនួលខុសត្រូវរបស់ម្ចាស់អគារតែម្នាក់ឯងនោះទេ។**<br>ទាំងម្ចាស់អាគារ និងអ្នកជួល សុទ្ធតែមានទំនួលខុសត្រូវ និងកាតព្វកិច្ចចំពោះមុខច្បាប់សម្រាប់លទ្ធភាពអាចចេញចូលបាននៃតំបន់សាធារណៈនៅក្នុងទីតាំងនោះ។ ប្រសិនបើអ្នកជួល ឬជួលអគារណាមួយ វាគឺជាការប្រសើរដែលអ្នកមានកិច្ចព្រមព្រៀងជាមួយម្ចាស់អគាររបស់អ្នកអំពីថាតើនរណាជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងថែទាំមុខងារទាំងឡាយដែលផ្តល់ភាពងាយស្រួលចេញចូលអគារនោះដល់ជនពិការ។ កិច្ចព្រមព្រៀងជួល និងជួលអគារត្រូវតែចែងថាតើអចលទ្រព្យត្រូវបានពិនិត្យដោយ CASp ដែរឬទេ ហើយប្រសិនបើពិនិត្យមែន ថាតើអចលទ្រព្យនោះគោរពតាមស្តង់ដារចេញចូលទាក់ទងនឹងសំណង់ដែលចូលជាធរមានទាំងអស់ដែរឬអត់។ |
| **ស្តង់ដារទាំងនេះតែងតែផ្លាស់ប្តូរជានិច្ច ដែលធ្វើឱ្យវាមានការលំបាកក្នុងការបន្តអនុលោមតាមច្បាប់។** | **ស្តង់ដារសំណង់សម្រាប់អគាររបស់អ្នកមិនមានការផ្លាស់ប្តូរនោះទេ។**<br>*ច្បាប់ ADA ត្រូវបានធ្វើបច្ចុប្បន្នភាពតែម្តងគត់ក្នុងរយៈពេលជាងម្ភៃឆ្នាំមកនេះ។ ទោះបីជាច្បាប់សាងសង់រដ្ឋកាលីហ្វ័រញ៉ាត្រូវបានធ្វើវិសោធនកម្មជាទៀងទាត់ក៏ដោយ ក៏ការអនុលោមតាមច្បាប់នៃអគាររបស់អ្នកត្រូវបានកំណត់ដោយច្បាប់សាងសង់ដែលមានជាធរមាននៅពេលដែលអគាររបស់អ្នកត្រូវបានសាងសង់ដំបូង ឬនៅពេលដែលមានការកែប្រែចុងក្រោយបំផុត។ អគារដែលធ្លាប់តែអនុលោមតាមច្បាប់រួចហើយ មិនត្រូវបានចាត់ទុកថាខុសច្បាប់នោះទេ ពីព្រោះបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីលទ្ធភាពអាចចេញចូលបានត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ ទោះជាយ៉ាងណាក៏ដោយ រាល់មុខងារអាចចេញចូលប្រើប្រាស់បានសម្រាប់ជនពិការត្រូវតែត្រូវបានថែទាំឱ្យស្ថិតក្នុងស្ថានភាពប្រើប្រាស់បានជានិច្ច។ CASp អាចកំណត់ស្ថានភាពនៃការគោរពតាមច្បាប់របស់អ្នកយោងទៅតាមស្តង់ដារជាធរមាន (ADA និងច្បាប់សាងសង់រដ្ឋកាលីហ្វ័រញ៉ា)។* |

DSA
DIVISION OF THE STATE ARCHITECT
DEPARTMENT OF GENERAL SERVICES

*សម្រាប់ព័ត៌មានបន្ថែម និងដើម្បីស្វែងរកអ្នកឯកទេស CASp នៅក្នុងតំបន់របស់អ្នក សូមចូលទៅកាន់គេហទំព័រ www.dgs.ca.gov/DSA/Resources/CASp-Property-Inspection*